ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី ១៧ លេខ ៥៧ ត្រីមាសទី ០៣ ឆ្នាំ ២០១៧

# រាជកិច្ច

ផ្សាយចេញពី

ទីស្ដីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ១~ព្រះរាជក្រម


២៨-០៧-២០១៧ -ព្រះរាជក្រម នស/រកម/០៧១៧/០០៧ ស្តីពី ការប្រកាសឱ្យប្រើ ច្បាប់ ស្តីពី វិសោធនកម្មច្បាប់ ស្តីពី គណបក្សនយោបាយ និងច្បាប់ ស្តីពី វិសោធកម្មច្បាប់ ស្តីពី គណបក្សនយោបាយ ៥៨៧០


### ២~ព្រះរាជក្រឹត្យ


២១-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៧៦ ស្តីពី ការតែងតាំង និងផ្តល់ឋានៈទីប្រឹក្សានៃក្រសួងពាណិជ្ជកម្ម ០២ រូប មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលយកប្រាក់បៀវត្សរ៍ ៥៨៧៤

២១-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៧៧ ស្តីពី ការតម្លើងឋានន្តរស័ក្តិ ឧត្តមសេនីយ៍ឯកដល់ឧត្តមសេនីយ៍ទោ **ម៉ែន រ៉ា** នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៥៨៧៥

២១-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៧៨ ស្តីពី ការផ្ទេរក្របខ័ណ្ឌលោក **ឈិត សុផល** នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងបរិស្ថាន មកឋានន្តរស័ក្តិ ឧត្តមសេនីយ៍ត្រីនាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៥៨៧៦

២១-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៧៩ ស្តីពី ការប្រោសព្រះរាជទាន នូវគ្រឿងឥស្សរិយយស តាមលំដាប់ថ្នាក់ ចំពោះ ឯកឧត្តម និងលោកជំទាវ ចំនួន ០៧ រូប ៥៨៧៧

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨២ ស្តីពី ការតម្លើងឋានន្តរស័ក្តិ នាយទាហានថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៦៥ រូប ៥៨៧៨

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨៣ ស្តីពី ការតែងតាំង និងផ្តល់ឋានៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ៥៨៨១

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨៤ ស្តីពី ការតម្លើងឋានៈលោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ជាទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ ទេសរដ្ឋមន្ត្រី ៥៨៨២

២៩-០៧-២០១៧ -ព្រះរាជក្រឹត្យ នស/រកត/០៧១៧/៥៨៥ ស្តីពី ការតែងតាំង និងផ្តល់ឋានៈជូនឯកឧត្តម **យូ សារម៉េត** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ អនុរដ្ឋលេខាធិការ ដោយមិន ទទួលប្រាក់បៀវត្សរ៍ ៥៨៨៣

## II~រាជរដ្ឋាភិបាល

### អនុក្រឹត្យ

២៥-០៧-២០១៧ -អនុក្រឹត្យលេខ ១១៦ អនក្រ.បក ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ៥៨៨៤

២៥-០៧-២០១៧ -អនុក្រឹត្យលេខ ១១៧ អនក្រ.បក ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស ៥៩០៤

២៧-០៦-២០១៧ -អនុក្រឹត្យលេខ ៦៧៤ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៩០៨

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៤ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ ៥៩០៩

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៥ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៩១១

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៦ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៩១២

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៧ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៩១៣

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៨ អនក្រ.តត ស្តីពី ការផ្ទេរភារកិច្ចមន្ត្រីរាជការ ៥៩១៤

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៤៩ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៩១៥

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥០ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៩១៦

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥១ អនក្រ.តត ស្តីពី ការតែងតាំងជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី ៥៩១៧

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥២ អនក្រ.តត ស្តីពី ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាលអាណត្តិទី ៧ នៃធនាគារអភិវឌ្ឍន៍ជនបទ ៥៩១៨

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៣ អនក្រ.តត ស្តីពី ការតែងតាំងមន្ត្រីរាជការ ៥៩២០

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៤ អនក្រ.តត ស្តីពី ការតែងតាំងមុខងារ នាយទាហាន ៥៩២១

២៦-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៥ អនក្រ.តត ស្តីពី ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា ៥៩២៣

២៧-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៦ អនក្រ.តត ស្តីពី ការជូនមេដាយសុវត្ថារា ៥៩២៥

២៧-០៧-២០១៧ -អនុក្រឹត្យលេខ ៧៥៧ អនក្រ.តត ស្តីពី ការជូនមេដាយមុនីសារាភ័ណ្ឌ ៥៩២៦

## III-ការងារបណ្ដាក្រសួង

### ១-ទីស្ដីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និង សិប្បកម្ម


០៨-០៥-២០១៧ -ប្រកាសលេខ ១៨៨ ឧស.កឧ.ប្រក ០៥ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូព្រីមៀរ ធូ (ខេមបូឌា) បង្កើតរោងចក្រ ផលិតស្បែកជើង ៥៩២៩

០៨-០៥-២០១៧ -ប្រកាសលេខ ១៨៩ ឧស.កឧ.ប្រក ០៥ ស្ដីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ម៉ាស្ទ័រ & ប្រៃង (ខេមបូឌា) បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ ៥៩៣២


### ២-ទីស្ដីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ


០៦-០៧-២០១៧ -ប្រកាសលេខ ៣៧៥ ប្រក.កសក ស្ដីពី គំរូពាក្យស្នើសុំ និងនីតិវិធីនៃការផ្ដល់វិញ្ញាបនបត្របញ្ជាក់គុណភាពពូជដំណាំ ៥៩៣៥

# ព្រះរាជក្រម

នស/រកម/០៧១៧/០០៧

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សម្ហោរិតាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំរដ្ឋសភាលើកទី៨ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៧ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៨៧/០២៧/២០១៧ កបធ.ច ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ច្បាប់

## ស្ដីពី

## វិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ

## និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីគណបក្សនយោបាយ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

ច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ១៩៩៧ និងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០៣១៧/០០៣ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

-មាត្រា ៦ថ្មី មាត្រា ១១ និងមាត្រា ៤៤ថ្មី ត្រូវបានកែប្រែ និងត្រូវបានបន្ថែម មាត្រា ៤៥ថ្មី(ស្ទួន) និងមាត្រា ៤៨ថ្មី(ស្ទួន) ដូចខាងក្រោម ៖

**មាត្រា ៦.- ថ្មី(ពីរ)**

គ្រប់គណបក្សនយោបាយមិនត្រូវធ្វើសកម្មភាពណាមួយដូចខាងក្រោម ៖

១-ធ្វើឲ្យមានអបគមន៍ ដែលនាំឲ្យអន្តរាយដល់ឯកភាពជាតិ និងបូរណភាពដែនដី ។

២-ធ្វើវិទ្ធង្សនាប្រឆាំងនឹងរបបប្រជាធិបតេយ្យ សេរី ពហុបក្ស និងរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ ។

៣-ធ្វើឲ្យប៉ះពាល់ដល់សន្តិសុខនៃរដ្ឋ ។

៤-បង្កើតកងកម្លាំងប្រដាប់អាវុធ ។

៥-ធ្វើការញុះញង់ដែលអាចនាំឲ្យមានការបែកបាក់ជាតិ ។

៦-ប្រើប្រាស់សារជាសម្លេង រូបភាព ឯកសារជាលាយលក្ខណ៍អក្សរ ឬសកម្មភាពរបស់ទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន ។

៧-យល់ព្រមដោយចំហ ឬដោយតុណ្ហីភាព ឬឃុបឃិតជាមួយទណ្ឌិតជាប់ទោសពីបទឧក្រិដ្ឋ ឬពីបទមជ្ឈិម ឲ្យធ្វើសកម្មភាពណាមួយដើម្បីជាផលប្រយោជន៍នយោបាយសម្រាប់គណបក្សនយោបាយរបស់ខ្លួន ។

៨-គាំទ្រ ឬរៀបចំផែនការ ឬឃុបឃិតជាមួយរាល់បុគ្គលដែលធ្វើសកម្មភាពក្នុងគោលបំណងប្រឆាំងនឹងផលប្រយោជន៍របស់ព្រះរាជាណាចក្រកម្ពុជា ដូចមានចែងពីចំណុចទី១ ដល់ចំណុចទី៥ ខាងលើ ។

**មាត្រា ១១.- ថ្មី**

គ្រប់គណបក្សនយោបាយត្រូវមានឈ្មោះ និងសញ្ញាសម្គាល់តាមការកំណត់ដូចខាងក្រោម ៖

១ -ឈ្មោះជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយ ត្រូវតែខុសគ្នាពីឈ្មោះជាអក្សរពេញ ឬអក្សរកាត់ និងសញ្ញាសម្គាល់របស់គណបក្សនយោបាយនានា ។

២-ឈ្មោះរបស់គណបក្សនយោបាយ មិនត្រូវធ្វើឡើងដោយគ្រាន់តែកែសម្រួលបន្តិចបន្តួចនៅលើឈ្មោះគណបក្សនយោបាយនានា ឬយកឈ្មោះរូបវន្តបុគ្គលមកដាក់ឡើយ ។

៣-សញ្ញាសម្គាល់របស់គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបភាពតំណាង

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ឲ្យសាសនា ប្រាសាទអង្គរវត្ត ឬព្រះឆាយាល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់អង្គ ឬរូបភាពរបស់រូបវ័ន្តបុគ្គលឡើយ ។

**មាត្រា ៤៤.– ថ្មី(ពីរ)**

ដោយមិនទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត គណបក្សនយោបាយដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៦ថ្មី(ពីរ) នៃច្បាប់នេះ និងមាត្រា៧ នៃច្បាប់ស្ដីពីគណបក្សនយោបាយ តុលាការអាចសម្រេចដូចខាងក្រោម ៖

-ផ្អាកសកម្មភាពគណបក្សនយោបាយនោះមិនលើសពី ៥(ប្រាំ)ឆ្នាំ ។
-រំលាយគណបក្សនយោបាយនោះ ។

**មាត្រា ៤៥.– ថ្មី(ស្ទួន)**

គណបក្សនយោបាយដែលត្រូវបានសម្រេចផ្អាកសកម្មភាព មិនត្រូវបានអនុញ្ញាតឲ្យចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតឡើយ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលគណបក្សនយោបាយនោះត្រូវបានសម្រេចផ្អាកសកម្មភាព ឬត្រូវបានសម្រេចរំលាយ ស្របតាមច្បាប់នេះ ។

**មាត្រា ៤៨.– ថ្មី(ស្ទួន)**

ចំពោះគណបក្សនយោបាយណាដែលមានឈ្មោះ ឬសញ្ញាសម្គាល់របស់គណបក្សនយោបាយជាឈ្មោះ ឬរូបភាពរបស់រូបវ័ន្តបុគ្គល ត្រូវធ្វើការផ្លាស់ប្ដូរឈ្មោះ ឬសញ្ញាសម្គាល់ ឲ្យស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ក្នុងរយៈពេល ៩០ (កៅសិប)ថ្ងៃ យ៉ាងយូរ គិតចាប់ពីថ្ងៃដែលច្បាប់នេះចូលជាធរមាន ។

**មាត្រាពីរ.–**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៧

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាស់បន្ទាប់**

**ប្រមុខរដ្ឋស្ដីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ**

នស.រកម.០៧១៧.៥៩៧

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្ដលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខៈ ៥៤៣ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ .ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៧៦

**យើង**

**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានទ្រង់យល់សេចក្ដីក្រាបបង្គំទូលថ្វាយ របស់សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា ១** : តែងតាំង និងផ្ដល់ឋានៈទីប្រឹក្សា នៃក្រសួងពាណិជ្ជកម្ម ០២រូប មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលយកប្រាក់បៀវត្សរ៍ ៖

១- ឯកឧត្តម **ហាន គឿក**

២- ឯកឧត្តម **ស៊ាង ឈុន**

**មាត្រា ២** : សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ដលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចារសា. ១៧០៧. ៥៥៦

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧*

លេខៈ ៥៧៦ ស.ណ
**សំណៅដែលមានតម្លៃជាការចេញផ្សាយ**
រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥១៧៧

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ **ឧត្តមសេនីយ៍ឯក** ដល់ ឧត្តមសេនីយ៍ទោ **ម៉ែន រ៉ា** អត្តលេខ ០០៤៧៣៣ នាយទាហានថ្នាក់ឧត្តមសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាតលេ. ១៧០៧. ៥៥៣

លេខៈ ៥៧៩ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ,ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៧៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រា១ :** ផ្ទេរក្របខ័ណ្ឌលោក **ឈិត សុផល** ពីឋានន្តរសក្តិវរៈមន្ត្រីថ្នាក់លេខ៣ នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល ក្រសួងបរិស្ថាន មកឋានន្តរសក្តិ **ឧត្តមសេនីយ៍ត្រី** អត្តលេខ ៧៨១៩៨ នាយនគរបាលថ្នាក់ឧត្តមសេនីយ៍ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧*

ចារណ. ១៧០៧. ៥៥៤

លេខ: ៥៧៨ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៧៩

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា)

ប្រោសព្រះរាជទាន

នូវ

ក-គ្រឿងឥស្សរិយយស **មុនីសារាភ័ណ្ឌ** ថ្នាក់ **មហាសេរីវឌ្ឍន៍** :

១- ឯកឧត្តម **គង់ កន្ថារ៉ា**
២- ឯកឧត្តម **អ៊ុន ធឹម**
៣- ឯកឧត្តម **ស្រី សូន**
៤- លោកជំទាវ **នេត្រ តូម៉ារី**
៥- ឯកឧត្តម **ជៀង វណ្ណដារ៉ុង**
៦- ឯកឧត្តម **ហ៊ី ធីរៈ**

ខ-គ្រឿងឥស្សរិយយស **ព្រះរាជាណាចក្រកម្ពុជា** ថ្នាក់ **មហាសេនា** :

១- លោកជំទាវ **ធីង ស៊ីមន**

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ចាស. ១៧/០៧. ៥៥៥

*ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០១៧*

លេខៈ ៥៨០ ស.ណ
សំណៅដែលមានតម្លៃជាការចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ កក្កដា ឆ្នាំ២០១៧
អគ្គលេខាធិការរាជរដ្ឋាភិបាល

សយ សុខា

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៨៥២

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី ០៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅ ចំពោះយោធិន នៃកងយោធពលខេមរភូមិន្ទ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តម្លើងឋានន្តរស័ក្តិ នាយទាហាន ថ្នាក់ឧត្តមសេនីយ៍ និងថ្នាក់វរសេនីយ៍ នៃកងយោធពលខេមរភូមិន្ទ ៖

**ក-ឋានន្តរស័ក្តិឧត្តមសេនីយ៍ទោ**

| | | | |
|---|---|---|---|
| ១-ឧត្តមសេនីយ៍ត្រី | **គី** | **សុខេន** | អត្តលេខ ០០៩៣២២ |
| ២-ឧត្តមសេនីយ៍ត្រី | **ម៉ី** | **វណ្ណៈ** | អត្តលេខ ០០៣១៥៣ |
| ៣-ឧត្តមសេនីយ៍ត្រី | **ជា** | **សារី** | អត្តលេខ ០០៣២៥៤ |
| ៤-ឧត្តមសេនីយ៍ត្រី | **ឡាំ** | **ឆេងលាភ** | អត្តលេខ ០១៦៦៤៣ |
| ៥-ឧត្តមសេនីយ៍ត្រី | **ញ៉ៀម** | **សាឡឿន** | អត្តលេខ ០០៨៨២២ |
| ៦-ឧត្តមសេនីយ៍ត្រី | **ព្រហ្ម** | **សុវណ្ណា** | អត្តលេខ ០៦៣០៥៣ |
| ៧-ឧត្តមសេនីយ៍ត្រី | **សេង** | **វុត្ថា** | អត្តលេខ ០០៩៤៤៣ |
| ៨-ឧត្តមសេនីយ៍ត្រី | **ញ៉ៀម** | **សុខុន** | អត្តលេខ ០០៣៨៧៤ |
| ៩-ឧត្តមសេនីយ៍ត្រី | **ឆាយ** | **ឡឿន** | អត្តលេខ ០១២០១៥ |
| ១០-ឧត្តមសេនីយ៍ត្រី | **សៅ** | **សារ៉េម** | អត្តលេខ ០១៤៩៩០ |
| ១១-ឧត្តមសេនីយ៍ត្រី | **ម៊ុន** | **ឃាង** | អត្តលេខ ០៣២៦៤៧ |
| ១២-ឧត្តមសេនីយ៍ត្រី | **ហៃ** | **ច័ន្ទតារិទ្ធ** | អត្តលេខ ០៣២៦១៧ |

១៣-ឧត្តមសេនីយ៍ត្រី **នួម សរពិសិដ្ឋ** អត្តលេខ ០១៧៦១២
១៤-ឧត្តមសេនីយ៍ត្រី **អ៊ិត សៅរី** អត្តលេខ ០០៥២៧២
១៥-ឧត្តមសេនីយ៍ត្រី **សីន្ធ ស៊ីថា** អត្តលេខ ០២១១៨៤
១៦-ឧត្តមសេនីយ៍ត្រី **ខន សាម៉ុន** អត្តលេខ ២៣២២៨៦
១៧-ឧត្តមសេនីយ៍ត្រី **លាង ស្រ៊ុន** អត្តលេខ ០១៦៥០០

**ខ-ឋានន្តរស័ក្តិឧត្តមសេនីយ៍ត្រី**

១-វរសេនីយ៍ឯក **ជួប សុគណ្ធ័** អត្តលេខ ០២២២៦៦
២-វរសេនីយ៍ឯក **ឡុង ម៉ាន់ថា** អត្តលេខ ០២២៨៩៩
៣-វរសេនីយ៍ឯក **ពៅ ស៊ីផាត** អត្តលេខ ០០៨៩២៨
៤-វរសេនីយ៍ឯក **គីម មុហាណារ៉ុង** អត្តលេខ ០១៦៤៩៥
៥-វរសេនីយ៍ឯក **ឌី សោភា** អត្តលេខ ០៥១៥៣៩
៦-វរសេនីយ៍ឯក **ផាត សុផា** អត្តលេខ ០១៦៦១៤
៧-វរសេនីយ៍ឯក **ច្រឹង សុន្ធរ៉ា** អត្តលេខ ០២៦៥០០
៨-វរសេនីយ៍ឯក **ហ៊ិន សុត** អត្តលេខ ០១៦៨៥៧
៩-វរសេនីយ៍ឯក **ម៉ា សម្បត្តិ** អត្តលេខ ០៣៤១៥៥
១០-វរសេនីយ៍ឯក **យ៉ា ធីវត្ត័** អត្តលេខ ០១២៨៩៤
១១-វរសេនីយ៍ឯក **សេង សារិទ្ធ** អត្តលេខ ០១២៨២៩
១២-វរសេនីយ៍ឯក **ឈាង ហ៊ីុយ** អត្តលេខ ០១៦៥៩៤
១៣-វរសេនីយ៍ឯក **ឈៀក ផេងលី** អត្តលេខ ០១០៤៨៧
១៤-វរសេនីយ៍ឯក **ឡុង សំណាង** អត្តលេខ ០០៩០២២
១៥-វរសេនីយ៍ឯក **រត្ន័ ចណ្ណោត** អត្តលេខ ០១៧៤១៩
១៦-វរសេនីយ៍ឯក **ហែម សារី** អត្តលេខ ០២៦៨៩៧
១៧-វរសេនីយ៍ឯក **ទៀប ហ៊ីត** អត្តលេខ ០៥០១១០
១៨-វរសេនីយ៍ឯក **តាំង សារិទ្ធ** អត្តលេខ ០១០៧២៨
១៩-វរសេនីយ៍ឯក **ចាន់ ប៉ូលី** អត្តលេខ ០០៩០៧១
២០-វរសេនីយ៍ឯក **រ័ត្ន ពុធតារា** អត្តលេខ ០១១៨៧៣
២១-វរសេនីយ៍ឯក **ហួរ ហេង** អត្តលេខ ១៨៦៤៨២
២២-វរសេនីយ៍ឯក **ព្រុំករុណា** អត្តលេខ ០១២២៨៤
២៣-វរសេនីយ៍ឯក **ជាតិ ចាម** អត្តលេខ ០០២៨៩៦
២៤-វរសេនីយ៍ឯក **ឡៅ ម៉ឺនម៉េង** អត្តលេខ ០១០៦១៧
២៥-វរសេនីយ៍ឯក **ឡោ សុផុល** អត្តលេខ ០២៣០៩៤
២៦-វរសេនីយ៍ឯក **ឃួន ធានី** អត្តលេខ ០១៥១៨៨
២៧-វរសេនីយ៍ឯក **ទូច សារឿន** អត្តលេខ ០០៣១៥៩
២៨-វរសេនីយ៍ឯក **គង់ សេន** អត្តលេខ ០៤៤៩២១
២៩-វរសេនីយ៍ឯក **សាន់ ស៊ី** អត្តលេខ ០១៥៥១៧
៣០-វរសេនីយ៍ឯក **រស់ តេង** អត្តលេខ ០២៩០១៤
៣១-វរសេនីយ៍ឯក **ជា ឧុឌ្ធី** អត្តលេខ ០១៦៥៨៨
៣២-វរសេនីយ៍ឯក **ថន ហេង** អត្តលេខ ០០៩៤១១

| | | | |
|---|---|---|---|
| ៣៣-វរសេនីយ៍ឯក | ផា | ច័ន្ទរ៉ា | អត្តលេខ ០៤៧០៥៥ |
| ៣៤-វរសេនីយ៍ឯក | នេត | ផុនា | អត្តលេខ ០៦៣៥៣៦ |
| ៣៥-វរសេនីយ៍ឯក | ឈិន | សំរេច | អត្តលេខ ០០៤៦៤០ |
| ៣៦-វរសេនីយ៍ឯក | តាន់ | សិរីសិទ្ធិ | អត្តលេខ ០១៨៤៤៧ |
| ៣៧-វរសេនីយ៍ឯក | ញ៉ាំអ៉ា | ឱត | អត្តលេខ ០០៤១៤៦ |
| ៣៨-វរសេនីយ៍ឯក | លឹម | នេងហ៊ត | អត្តលេខ ០២៥៦៧៩ |
| ៣៩-វរសេនីយ៍ឯក | ហោ | សុផល្គុណ | អត្តលេខ ០២៥៧១៥ |
| ៤០-វរសេនីយ៍ឯក | ចាន់ | ប្រុស | អត្តលេខ ១៦១៣១៣ |
| ៤១-វរសេនីយ៍ឯក | នូ | សុផល | អត្តលេខ ០០៩៥៧៤ |
| ៤២-វរសេនីយ៍ឯក | សុខ | ប្រសិទ្ធិ | អត្តលេខ ០០៣៨៣៦ |
| ៤៣-វរសេនីយ៍ឯក | ស្រី | កុសល | អត្តលេខ ០៨៣២៨៣ |
| ៤៤-វរសេនីយ៍ឯក | ទ្រិញ | ឈុន | អត្តលេខ ០០១៣៦៩ |
| ៤៥-វរសេនីយ៍ឯក | សំ | ហ៊ីសេង | អត្តលេខ ០២១១៩០ |
| ៤៦-វរសេនីយ៍ឯក | អោក | សំណាង | អត្តលេខ ០៤៣០០២ |
| ៤៧-វរសេនីយ៍ឯក | រិទ្ធ | ឌីការ | អត្តលេខ ១៧៧៨៣៤ |
| ៤៨-វរសេនីយ៍ឯក | ម៉ុក | សារឿន | អត្តលេខ ០០៤៦៦៣ |

**មាត្រា២:** សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៧

**ក្នុងព្រះបរមនាម និងតាមព្រះរាជបន្ទូលត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

នស.រកត.០៧១៧.៥៩១

លេខ: ៥៩៩ ស.ណ

**សំណៅចំលងចេញតាមច្បាប់ដើម**

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៤៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៥/១១១ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា៤ មាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៤ មាត្រា១៧ និងមាត្រា២០ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិត្យសភាកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ ទូច** ជាប្រធានរាជបណ្ឌិត្យសភាកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

ចរណ.១៧០៧.៥៩២

**លេខ:** ៥៤៧ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៥៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៤/១៤៩៣ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីការគ្រប់គ្រងនិងការបើកផ្តល់ប្រាក់បំណាច់ជូនទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ដំឡើងឋានៈលោកជំទាវបណ្ឌិតសភាចារ្យ **ខ្លូត ធីតា** ទីប្រឹក្សាផ្ទាល់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មានឋានៈស្មើ **ទេសរដ្ឋមន្ត្រី** ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

៧នស.១៧០៧.៥៩៣

លេខ: ៥៧៦ ស.ណ

សំណៅដែលមានតម្លៃជាការចែកផ្សាយ

រាជធានីភ្នំពេញ ,ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**ស៊យ សុខា**

# ព្រះរាជក្រឹត្យ

នស/រកត/០៧១៧/៥៩៥

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** តែងតាំង និងផ្តល់ឋានៈជូនឯកឧត្តម **យូ សារ៉េត** ជាទីប្រឹក្សាសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយមិនទទួលប្រាក់បៀវត្សរ៍ ។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៧*

**ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់**
**ប្រមុខរដ្ឋស្តីទី**

៧ នស. ១៧០៧.៥៩៥

**ហត្ថលេខា និងព្រះរាជលញ្ឆករ**
**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

លេខ: ៥៩១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០១៧
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ : ១១៦ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ២៤អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ២៣៤អនក្រ.បក ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១ .-**

អនុក្រឹត្យនេះកំណត់ពីឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត សម្រាប់ប្រើប្រាស់បំពេញការងារ ចុះអនុវត្តច្បាប់ អនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត និងលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធវិស័យភាពយន្តក្នុងព្រះរាជាណាចក្រកម្ពុជា។

**ជំពូកទី២**

**ឯកសណ្ឋាន**

**មាត្រា២ .-**

ឯកសណ្ឋានរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

**ក. ចំពោះបុរស**

១. អាវ មាន២(ពីរ)ប្រភេទ៖

- អាវដៃខ្លី
- អាវដៃវែង

១.១. អាវដៃខ្លី

អាវដៃខ្លីផលិតពីសាច់ក្រណាត់ពណ៌ឈាមជ្រូក កាត់ជាទម្រង់អាវធម្មតាដៃខ្លី កឱប មានហោប៉ៅចំនួន២នៅខាងលើដេរជាលក្ខណៈប៉ះបត់ជាពីផ្នត់ឆ្វេងស្តាំ គម្របស្លឹកពោធិ៍ ដាក់ឡេវពណ៌ដូចអាវ(រូបភាពទី១ក្នុងឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់សម្រាប់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តបំពេញការងារប្រចាំថ្ងៃ ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងកម្មវិធីនីមួយៗ។

១.២. អាវដៃវែង

អាវដៃវែងផលិតពីសាច់ក្រណាត់ពណ៌ឈាមជ្រូក កាត់ជាទម្រង់អាវធម្មតាដៃវែង កឱប មានហោប៉ៅចំនួន២នៅខាងលើដេរជាលក្ខណៈប៉ះបត់ជាពីផ្នត់ឆ្វេងស្តាំ គម្របស្លឹកពោធិ៍ ដាក់ឡេវពណ៌ដូចអាវ(រូបភាពទី២ក្នុងឧបសម្ព័ន្ធទី១)។ ឯកសណ្ឋាននេះប្រើប្រាស់ សម្រាប់មន្ត្រី ត្រួតពិនិត្យឧស្សាហកម្មភាពយន្តបំពេញការងារប្រចាំថ្ងៃ ពិធីបុណ្យជាតិ សន្និបាត សវនាការ និងករណីតម្រូវក្នុងកម្មវិធីនីមួយៗ។

២. ខោជើងវែង

ខោជើងវែងផលិតពីសាច់ក្រណាត់ពណ៌ទឹកប៊ិចចាស់ ចង្កេះត ដេរថ្នេរបង្កប់ជីបក្លីខាងមុខពីរ មានហោប៉ៅបី ហោប៉ៅចំហៀងទាំងសងខាងដេរបញ្ឆិតតាមថ្នេរ ចំហៀងខោ និងហោប៉ៅក្រោយ ដេរថ្នេរបង្កប់នៅខាងស្តាំ និងមានឡេវមួយបង្កប់(រូបភាពទី៣ ឧបសម្ព័ន្ធទី១)។

៣. ស្បែកជើង

ស្បែកជើងឃ្លុបធ្វើពីស្បែកពណ៌ខ្មៅ កខ្លី មានចងខ្សែ មានកែងទាបកម្ពស់៣០មីលីម៉ែត្រ និងមានស្រោមជើងពណ៌ខ្មៅ(រូបភាពទី៤ ឧបសម្ព័ន្ធទី១)។

៤. ខ្សែក្រវ៉ាត់

ខ្សែក្រវ៉ាត់ផលិតពីស្បែក ពណ៌ខ្មៅ មានក្បាលពណ៌ទឹកប្រាក់(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

**ខ. ចំពោះស្ត្រី**

១. អាវមាន២(ពីរ)ប្រភេទ៖

- អាវដៃខ្លី ដូចបុរស តែមានជីបរាង(រូបភាពទី៦ ឧបសម្ព័ន្ធទី១)
- អាវដៃវែង ដូចបុរស តែមានជីបរាង(រូបភាពទី៧ ឧបសម្ព័ន្ធទី១)

២. ខោ

មានលក្ខណៈដូចជាខោបុរសពណ៌ទឹកប៊ិចចាស់(រូបភាពទី៨ ឧបសម្ព័ន្ធទី១)

៣. សំពត់

មានពណ៌ទឹកប៊ិចចាស់ កាត់សំពត់រាងតចង្កេះសម្រុងចុះក្រោមដល់ពាក់កណ្ដាលស្មងជើង ផ្នែកខាងក្រោយមានរូតនៅចំហៀង(រូបភាពទី៩ ឧបសម្ព័ន្ធទី១)

៤. ស្បែកជើង

ស្បែកជើងឃ្លុប ធ្វើពីស្បែកពណ៌ខ្មៅ គ្មានចងខ្សែ កខ្លី ឃ្លុបមុខក្រោយមានកែងទាបកម្ពស់កែង៣០មីល្លីម៉ែត្រ(រូបភាពទី១០ ឧបសម្ព័ន្ធទី១)។

៥. ខ្សែក្រវ៉ាត់

មានលក្ខណៈដូចខ្សែក្រវ៉ាត់បុរស(រូបភាពទី៥ ឧបសម្ព័ន្ធទី១)។

## ជំពូកទី៣
## សញ្ញាសម្គាល់

**មាត្រា៣ .-**

សញ្ញាសម្គាល់របស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ត្រូវបានកំណត់ដូចខាងក្រោម៖

១- ស្លាកសញ្ញាសម្គាល់រូបសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ត្រូវប៉ាក់លើសាច់ក្រណាត់រាងមូលដែលមានទំហំអង្កត់ផ្ចិត៧សង្ទីម៉ែត្រ ដោយដេរភ្ជាប់ពីលើដើមដៃអាវខាងស្ដាំ(រូបភាពទី១១ ឧបសម្ព័ន្ធទី២)។

២- សញ្ញាសម្គាល់និមិត្តសញ្ញាជាអក្សរ **ត្រួតពិនិត្យឧស្សាហកម្មភាពយន្ត** ជាប៉ាក់សម្រាប់ដេរប៉ះលើដៃអាវខាងឆ្វេងមានប្រវែង៥០មិល្លីម៉ែត្រពីថ្នេរស្មាអាវ ក្រណាត់ប៉ាក់កម្ពស់២២មិល្លីម៉ែត្រ និងមានទទឹង១០៥មិល្លីម៉ែត្រ(រូបភាពទី១២ ឧបសម្ព័ន្ធទី២)។

៣- ស្លាកសញ្ញាសម្គាល់សម្រាប់ខ្ទាស់លើហោប៉ៅអាវខាងស្ដាំមានរាងមូលប៉ោង ទំហំ៥៥មិល្លីម៉ែត្រ ធ្វើពីលោហជាតុ ភ្ជាប់ដោយបន្ទះស្បែកមានទម្រង់ជានិមិត្តសញ្ញាអក្សរ **ត្រួតពិនិត្យឧស្សាហកម្មភាពយន្ត** នៅផ្នែកខាងលើ នៅចំកណ្ដាលមានស្លាកសញ្ញាសម្គាល់រូបសញ្ញា នាយកដ្ឋានសិល្បៈភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ និងផ្នែកខាងក្រោមមានអក្សរ FILM INDUSTRY CONTROL (រូបភាពទី១៣ ឧបសម្ព័ន្ធទី២)។

៤- ផ្លាកសញ្ញាសម្គាល់ឈ្មោះសម្រាប់ **មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

ផ្លាកសញ្ញាឈ្មោះមន្ត្រី សម្រាប់ពាក់នៅពីលើហោប៉ៅអាវខាងស្ដាំមានរាងចតុកោណកែង ដែលមានបណ្ដោយ៨០មិល្លីម៉ែត្រ ទទឹង២៥មិល្លីម៉ែត្រដែលសរសេរអក្សរពណ៌មាស និងពាសដោយជ័រវ៉ឹងថ្លាមានផ្ទៃពណ៌ខៀវចាស់ និងមានខ្សែបន្ទាត់ស្ដែងពណ៌មាសព័ទ្ធជុំវិញដែលមានទំហំ០,១៥មិល្លីម៉ែត្រ មានសរសេរគោត្តនាម និងនាមជាអក្សរខ្មែរ អក្សរឡាតាំង និងលេខសម្គាល់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត (រូបភាពទី១៤ ឧបសម្ព័ន្ធទី២)។

## ជំពូកទី៤
## សញ្ញាសក្តិ

**មាត្រា៤ .-**

សញ្ញាសក្តិត្រូវបានរៀបចំជា៥(ប្រាំ)ថ្នាក់ប្រើបានទាំងបុរសនិងស្ត្រី(រូបភាពទី៤ ឧបសម្ព័ន្ធទី១)

១. ថ្នាក់ប្រធាននាយកដ្ឋាន/

ម្ជុកកន្ទឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតម្ជុកកន្ទឹបខាងលើ )។ ផ្នែកខាងក្រោមស្លាកសញ្ញាមានប៉ាក់កម្រងក្បាច់ខ្សែសយពណ៌មាស នៅខាងចុងសងខាងនៃខ្សែសយនេះ មានភ្ជាប់ដោយឡេវរូបព្រះសង្ការពណ៌មាស។ នៅលើក្បាំងម្ជុកមានប៉ាក់ភ្ញីទេសឱនពណ៌មាស ទម្រង់ស្នែងក្របីដល់ជើងម្ជុក។

**២. ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

ម្ជុកកន្ទឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតម្ជុកកន្ទឹបខាងលើ )។ នៅលើក្បាំងម្ជុកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកមាស ទម្រង់ស្នែងក្របីដល់ជើងម្ជុក។

**៣. ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្តាលនិងអនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

ម្ជុកកន្ទឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតម្ជុកកន្ទឹបខាងលើ )។ នៅលើក្បាំងម្ជុកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកមាស ទម្រង់ស្នែងក្របីដល់ពាក់កណ្តាលជើងម្ជុក។

**៤. ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្តាលនិងប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

ម្ជុកកន្ទឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតម្ជុកកន្ទឹបខាងលើ )។ នៅលើក្បាំងម្ជុកមានប៉ាក់ភ្ញីទេសឱនពណ៌ទឹកប្រាក់ ទម្រង់ស្នែងក្របីដល់ពាក់កណ្តាលជើងម្ជុក។

**៥. ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត**

ម្ជុកកន្ទឹបធ្វើពីសាច់ក្រណាត់ពណ៌ខ្មៅ ផ្នែកខាងមុខមានភ្ជាប់ស្លាកសញ្ញាក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានទំហំអង្កត់ផ្ចិត៥៥មិល្លីម៉ែត្រ( ខ្នាតម្ជុកកន្ទឹបខាងលើ ) និងនៅលើក្បាំងម្ជុកគ្មានប៉ាក់ភ្ញីទេសទេ។

## ជំពូកទី៥
## ការប្រើប្រាស់ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ

**មាត្រា៥ .-**

ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ត្រូវបានប្រើប្រាស់ដោយមន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ដែលបម្រើការនៅនាយកដ្ឋានសិល្បភាពយន្តនិងផ្សព្វផ្សាយវប្បធម៌ និងមន្ត្រីទទួលបន្ទុកភាពយន្តនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ប្រើប្រាស់សម្រាប់៖

១- បំពេញការងារប្រចាំថ្ងៃក្នុងអង្គភាព។

២- បំពេញបេសកកម្មពង្រឹងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងឧស្សាហកម្មភាពយន្ត និងច្បាប់នានាពាក់ព័ន្ធក្នុងប្រតិបត្តិការ ស្រាវជ្រាវ តាមដាន ស៊ើបអង្កេត ត្រួតពិនិត្យ និងបង្ក្រាបបទល្មើសក្នុងវិស័យភាពយន្ត។

៣- ចូលរួមពិធីបុណ្យជាតិ ប្រជុំ និង/ឬ សន្និសីទផ្លូវការផ្សេងៗទៀត។

៤- ចូលរួមក្នុងសវនាការតុលាការ។

**មាត្រា៦ .-**

មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តម្នាក់ៗ ត្រូវទទួលបានឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិ ដូចមានចែងក្នុងអនុក្រឹត្យនេះចំនួន២( ពីរ )សម្រាប់ ដើម្បីប្រើប្រាស់ក្នុងរយៈពេល១( មួយ )ឆ្នាំ តាមទំហំនៃថវិកាជាតិប្រចាំឆ្នាំដែលបានវិភាជជូន។

**មាត្រា៧ .-**

ក្នុងពេលបំពេញបេសកកម្មមន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្តត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងមានបណ្ណសម្គាល់ខ្លួនមន្ត្រីរាជការ ព្រមទាំងលិខិតបញ្ជាបេសកកម្ម។

## ជំពូកទី៦
## ទោសប្បញ្ញត្តិ

**មាត្រា៨ .-**

ជនណាដែលបានក្លែងឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ ឬក្លែងបន្លំខ្លួនដោយស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ ឬសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**ភឿង សកុណា**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# រូបភាពទី១ ឧបសម្ព័ន្ធទី១

## នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

## ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

## អាវដៃខ្លីបុរស



មើលពីខាងមុខ មើលពីខាងក្រោយ

## រូបភាពទី២ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

អាវដៃវែងបុរស



មើលពីខាងមុខ



មើលពីខាងក្រោយ

# រូបភាពទី៣ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**ខោជើងវែងបុរស**



មើលខាងពីមុខ មើលពីខាងក្រោយ

## រូបភាពទី៤ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ស្បែកជើងនិងស្រោមជើងបុរស



ស្បែកជើង



ស្រោមជើង

## រូបភាពទី៥ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ខ្សែក្រវ៉ាត់បុរសនិងស្ត្រី



# រូបភាពទី៦ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

អាវដៃខ្លីស្ត្រី



មើលពីខាងមុខ



មើលពីខាងក្រោយ

# រូបភាពទី៧ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក. ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

**ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត**

**អាវដៃវែងស្ត្រី**



មើលពីខាងមុខ



មើលពីខាងក្រោយ

## រូបភាពទី៨ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ខោជើងវែងស្ត្រី



មើលខាងពីមុខ មើលពីខាងក្រោយ

## រូបភាពទី៩ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

សំពត់បំពង់ស្ត្រី



មើលខាងពីមុខ



មើលពីខាងក្រោយ

## រូបភាពទី១០ ឧបសម្ព័ន្ធទី១

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្ដីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្ដិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ស្បែកជើងកែងចោតស្ត្រី



## រូបភាពទី១១ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

សញ្ញាសម្គាល់ លើដៃអាវខាងស្តាំ



# រូបភាពទី១២ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

សញ្ញាសម្គាល់ លើដៃអាវខាងឆ្វេង



## រូបភាពទី១៣ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ ១១៦ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

ស្លាកសញ្ញា មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត



## រូបភាពទី១៤ ឧបសម្ព័ន្ធទី២

### នៃអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កក្កដា ឆ្នាំ២០១៧

### ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

### ស្លាកឈ្មោះ មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត



# រូបភាពទី១៥ ឧបសម្ព័ន្ធទី២

នៃអនុក្រឹត្យលេខ១១៦អនក្រ.បក ចុះថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០១៧

ស្តីពី ឯកសណ្ឋាន សញ្ញាសម្គាល់ និងសញ្ញាសក្តិរបស់មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត

សញ្ញាសក្តិ មន្ត្រីត្រួតពិនិត្យឧស្សាហកម្មភាពយន្ត



ថ្នាក់ប្រធាននាយកដ្ឋាន



ថ្នាក់អនុប្រធាននាយកដ្ឋាននិងប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់ប្រធានការិយាល័យថ្នាក់កណ្ដាលនិងអនុប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់អនុប្រធានការិយាល័យថ្នាក់កណ្ដាលនិងប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត



ថ្នាក់មន្ត្រីនិងអនុប្រធានការិយាល័យនៃមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ** : ១១៧.អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការរៀបចំនិងការប្រព្រឹត្តទៅនៃវិទ្យាស្ថានជាតិអប់រំពិសេស**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៩/០១០ ចុះថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០០៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារនិងលើកកម្ពស់សិទ្ធិជនពិការ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/៣៤០ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០១/៣៤១ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០០១ ស្តីពីលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើតនិងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សានិងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន

- បានឃើញអនុក្រឹត្យលេខ៥៨ អនក្រ.បក ចុះថ្ងៃទី៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធការគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួងស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

គ្រូវបានបង្កើតវិទ្យាស្ថានជាតិអប់រំពិសេស ដែលសរសេរជាអក្សរកាត់ថា **វ.ជ.អ.ព.** ហើយដែលសរសេរជាភាសាអង់គ្លេសថា National Institute for Special Education និងជាអក្សរកាត់ថា N.I.S.E.។

**វ.ជ.អ.ព.** ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**វ.ជ.អ.ព.** មានទីតាំងបច្ចុប្បន្នស្ថិតនៅដីឡូលេខ៨៥៩ ផ្លូវភ្នំពេញហាណូយ ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

## ជំពូកទី២
## តួនាទីនិងភារកិច្ច

**មាត្រា២ .-**

**វ.ជ.អ.ព.** មានតួនាទីជាសេនាធិការឱ្យក្រសួងអប់រំ យុវជន និងកីឡាលើការបណ្តុះបណ្តាលនិងវិក្រឹតការក្របខណ្ឌគ្រូបង្រៀនសម្រាប់បង្រៀនសិស្ស និស្សិតពិការ និងមានភារកិច្ចដូចតទៅ៖

- បណ្តុះបណ្តាលគ្រូបង្រៀនគ្រប់កម្រិតសិក្សាសម្រាប់ជនពិការ
- វិក្រឹតការបុគ្គលិកអប់រំគ្រប់កម្រិតសិក្សាសម្រាប់ជនពិការ
- អភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំលើការងារអប់រំជនពិការ
- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការឱ្យស្របតាមស្តង់ដាសមត្ថភាពកម្រិតគុណវុឌ្ឍជាតិ និងតម្រូវការទីផ្សារការងារសម្រាប់ជនពិការ
- បណ្តុះបណ្តាលវិជ្ជាជីវៈបុគ្គលិកអប់រំក្នុងវិទ្យាស្ថាន
- ពិនិត្យតាមដាននិងវាយតម្លៃការងារបណ្តុះបណ្តាលនិងវិក្រឹតការបុគ្គលិកអប់រំសម្រាប់ជនពិការ
- សិក្សាស្រាវជ្រាវនិងអភិវឌ្ឍសញ្ញាណថ្មី ផ្នែកភាសា សញ្ញាខ្មែរ ឧបករណ៍ជំនួយ និងសម្ភារៈឧបទេសនានាសម្រាប់អប់រំជនពិការ
- កសាងបណ្តាញកិច្ចសហប្រតិបត្តិការជាតិនិងអន្តរជាតិដើម្បីធានាគុណភាពបណ្តុះបណ្តាលគ្រូបង្រៀនសម្រាប់ជនពិការ
- កសាងនិងអនុវត្តផែនការអភិវឌ្ឍវិទ្យាស្ថានជាតិអប់រំពិសេសរយៈពេលខ្លី មធ្យម និងវែង
- លើកគម្រោងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការវិទ្យាស្ថាន
- គ្រប់គ្រងបុគ្គលិក គ្រូបង្រៀន កម្មករ គរុសិស្ស គរុនិស្សិត និងទ្រព្យសម្បត្តិរបស់វិទ្យាស្ថាន

- កៀរគរធនធានពីប្រភពផ្សេងៗសម្រាប់គាំទ្រការបណ្តុះបណ្តាលនិងការស្រាវជ្រាវអប់រំជនពិការ
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

## ជំពូកទី៣
## រចនាសម្ព័ន្ធនិងការគ្រប់គ្រង

**មាត្រា៣ .-**

**ទ.ជ.អ.ព.** ត្រូវរៀបចំកម្មវិធីបណ្តុះបណ្តាលនិងវិក្រឹតការក្របខណ្ឌគ្រូបង្រៀន តាមប្រព័ន្ធ ១២+៤ ដោយអនុលោមតាមក្របខណ្ឌគុណវុឌ្ឍជាតិ។

យន្តការ នីតិវិធី និងកម្មវិធីនៃការបណ្តុះបណ្តាលនិងវិក្រឹតការ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤ .-**

**ទ.ជ.អ.ព.** ត្រូវដឹកនាំដោយនាយក១(មួយ)រូប មានឋានៈស្មើប្រធាននាយកដ្ឋាននិងនាយករងច្រើនបំផុត៥(ប្រាំ)រូប ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**ទ.ជ.អ.ព.** មានដេប៉ាតឺម៉ង់និងការិយាល័យមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ដេប៉ាតឺម៉ង់និងការិយាល័យចំណុះវិទ្យាស្ថានជាតិអប់រំពិសេសត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥ .-**

**ទ.ជ.អ.ព.** ត្រូវមានក្រុមប្រឹក្សាបច្ចេកទេសមួយដើម្បីជួយពិនិត្យ ផ្តល់យោបល់ និងតម្រង់ទិសលើការងារបណ្តុះបណ្តាលឱ្យស្របតាមគោលនយោបាយផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាពនិងកម្មវិធីសិក្សារបស់វិទ្យាស្ថាន។

សមាសភាពនិងភារកិច្ចរបស់ក្រុមប្រឹក្សាបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៦ .-**

**ទ.ជ.អ.ព.** មានសិទ្ធិប្រើត្រាដោយឡែកសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា៧ .-**

គរុសិស្ស គរុនិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ ត្រូវទទួលបានសញ្ញាបត្រវិជ្ជាជីវៈគ្រូបង្រៀនសម្រាប់ជនពិការតាមកម្រិតនិងមុខជំនាញដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយវិទ្យាស្ថានជាតិអប់រំពិសេស ផ្អែកលើបញ្ជីឈ្មោះគរុសិស្ស គរុនិស្សិតដែលបានបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដោយមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៨ .-**

ការចំណាយសម្រាប់ដំណើរការរបស់វិទ្យាស្ថានជាតិអប់រំពិសេស ត្រូវផ្គត់ផ្គង់ដោយថវិកាជាតិក្នុងគម្រោងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**ទ.ជ.អ.ព.** មានសិទ្ធិទទួលនិងចាត់ចែង ប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធានដែលបានមកពីប្រភពស្របច្បាប់ផ្សេងៗទៀត សម្រាប់ដំណើរការការងាររបស់ខ្លួន។

**ជំពូកទី៤**

**អវសានប្បញ្ញត្តិ**

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**ហង់ ជួន ណារ៉ុន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦៣៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីននិងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្មមាត្រា ៤, ១០ និង ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/ ១៦០ ចុះថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការ ដោយសារមីន
- យោងតាមសំណើរបស់អនុប្រធានទី ១ អាជ្ញាធរមីន

## សម្រេច

**មាត្រា ១**: តែងតាំងលោកស្រី **ម៉េង ថាវី** ជាទីប្រឹក្សាអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការ ដោយសារមីនមានឋានៈស្មើ អគ្គនាយករង បន្ថែមលើមុខងារបច្ចុប្បន្ន ។

**មាត្រា ២**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ អគ្គលេខាធិការដ្ឋានអាជ្ញាធរមីន និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៤៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ច និងតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចមន្ត្រីរាជការចំនួន ០២រូប ដូចមានរាយនាមខាងក្រោមៈ

១-លោក **ពេជ ហាន** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ពីអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់ ឱ្យទៅបម្រើការងារនៅទីស្តីការក្រសួងមហាផ្ទៃ

២-លោក **សាយ សុជាតិ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ១ ពីអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង ឱ្យទៅកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់។

**មាត្រា ២ :** តែងតាំងលោក **គិត សុផា** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តពោធិ៍សាត់។

**មាត្រា ៣ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **យិន សុទិនចិន្តា** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ១ ពីអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង មកជាអគ្គនាយករង នៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៩៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ផុន លីវិរៈ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ពីអភិបាលរង នៃគណៈអភិបាលខេត្តកោះកុង មកជាអគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម ក្រសួងមហាផ្ទៃ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៧៤៣ អនក្រ.តត

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **ជាម ច័ន្ទសោភ័ណ** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៥ ពីអភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង ឲ្យទៅកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តត្បូងឃ្មុំ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៣៤៨ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ចមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** ផ្ទេរភារកិច្ចលោក **អ៊ុយ សុធាវី** ឋានន្តរស័ក្តិឧត្តមមន្ត្រី ថ្នាក់លេខ៦ ពីអភិបាលរង នៃគណៈអភិបាលខេត្តត្បូងឃ្មុំ ឱ្យទៅកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តបាត់ដំបង។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦៧/៤៩៨.អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោកស្រី **គា សុគន្ធ** ឋានន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ២ ឲ្យកាន់មុខតំណែងជាអភិបាលរង នៃគណៈអភិបាលខេត្តតាកែវ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧៤០ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៩ ស្តីពីការកំណត់ចំនួនគណៈអភិបាលរាជធានី គណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក គណៈអភិបាលខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១ :** តែងតាំងលោក **ហាន ពិសិដ្ឋ** ឋាននន្តរស័ក្តិវរមន្ត្រី ថ្នាក់លេខ៣ ឱ្យកាន់មុខតំណែងជាអភិបាល នៃគណៈអភិបាលស្រុកភ្នំស្រួច នៃខេត្តកំពង់ស្ពឺ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានឈ្មោះក្នុងមាត្រា១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៥ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់

## សម្រេច

**មាត្រា១.-**

តែងតាំងជំនួយការអមទីស្តីការគណៈរដ្ឋមន្ត្រីចំនួន ០២រូប ដូចមានរាយនាមខាងក្រោម ÷

១. លោក **តឹក តុងលីម** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២. លោក **នាង ស៊ន** មានឋានៈស្មើ ប្រធាននាយកដ្ឋាន។

**មាត្រា២.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧៥២ អនក្រ.បក

**អនុក្រឹត្យ**
**ស្តីពី**
**ការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អាណត្តិទី ៧**
**នៃធនាគារអភិវឌ្ឍន៍ជនបទ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម//០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩៩ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៤ស្តីពីធនាគារអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ ១០១៨ អនក្រ.បក ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការតែងតាំងអគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានតែងតាំងប្រធាន និងសមាជិកក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍ជនបទ អាណត្តិទី ៧ ដែលមានសមាសភាពដូចខាងក្រោម÷

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **រស់ សីលវ៉ា** | អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម | **សាន វិសាល** | អនុរដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣- ឯកឧត្តម | **កៅ ថាច** | អគ្គនាយកនៃធនាគារអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៤- លោក | **សរ ចិត្រា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៥- លោក | **ឆាន សុសេរី** | អនុប្រធាននាយកដ្ឋានទប់ស្កាត់ បង្ការ និងអប់រំ នៃ អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយទំនាស់ ដីធ្លី និងជាជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី-ប្រចាំការ | សមាជិក |
| ៦- លោក | **អោម សេខបូរ៉ា** | តំណាងអភិបាលឯករាជ្យ | សមាជិក |

**មាត្រា ២.-**

អនុក្រឹត្យលេខ ១១៦១.អនក្រ.តត. ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល អាណត្តិទី ៦ និងទីប្រឹក្សាជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍ជនបទ និង បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ដូចប្រការ ៣ “ដើម្បីអនុវត្ត”
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ :** ៧៥៣ អនក្រ.តត

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រង នៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១ .-** តែងតាំងមន្ត្រីរាជការ ចំនួន ០២ រូប របស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ដូចមានរាយនាមខាងក្រោម៖

១- លោក **ហ៊ីន ឈឿន** ជាអគ្គនាយករង នៃអគ្គនាយកដ្ឋានបច្ចេកទេស

២- លោក **ខ៊ាន់ ណូរ៉ាក់** ជានាយកអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៧៥៤ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមុខងារ នាយទាហាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសម្រួលតួនាទី ភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១ :** តែងតាំងមុខងារ នាយទាហាន នៃកងយោធពលខេមរភូមិន្ទ ដែលមានរាយនាមដូចខាងក្រោម៖

| | | | | |
|---|---|---|---|---|
| ១-ឧត្តមសេនីយ៍ទោ | **គិន លឹមហុង** | អត្តលេខ ០០០៥៤៧ | ជា ទីប្រឹក្សា ក្រសួងការពារជាតិ |
| ២-ឧត្តមសេនីយ៍ត្រី | **មុំ សារ៉ន** | អត្តលេខ ០១០៣៦៣ | ជា មេបញ្ជាការរង យោធភូមិភាគពិសេស |
| ៣-ឧត្តមសេនីយ៍ត្រី | **សុខ ឃឿន** | អត្តលេខ ០១២៨៧៧ | ជា មេបញ្ជាការរង យោធភូមិភាគពិសេស |
| ៤-ឧត្តមសេនីយ៍ត្រី | **ឡេង គន្ធាវរិទ្ធ** | អត្តលេខ ០០៣១៧៩ | ជា មេបញ្ជាការរង យោធភូមិភាគពិសេស |
| ៥-ឧត្តមសេនីយ៍ត្រី | **កៅ ឆុន** | អត្តលេខ ០០៣១៨៥ | ជា មេបញ្ជាការរង យោធភូមិភាគពិសេស |
| ៦-ឧត្តមសេនីយ៍ត្រី | **ឌឹម អាត** | អត្តលេខ ០០១១៥៣ | ជា មេបញ្ជាការរង យោធភូមិភាគពិសេស |
| ៧-ឧត្តមសេនីយ៍ត្រី | **ជូប ពិសិដ្ឋ** | អត្តលេខ ០០២៤៤០ | ជា នាយសេនាធិការរង បញ្ជាការដ្ឋានកងទ័ពជើងអាកាស |
| ៨-ឧត្តមសេនីយ៍ត្រី | **ណុប ឧឬទ្ធិដ្ឋ** | អត្តលេខ ០០០៨៥០ | ជា នាយសេនាធិការរង បញ្ជាការដ្ឋានកងទ័ពជើងអាកាស |

៩-ឧត្តមសេនីយ៍ត្រី **សៅ** **ឧុទ្ធា** អត្តលេខ ០០២៤៤៣ ជា នាយសេនាធិការរង
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១០-ឧត្តមសេនីយ៍ត្រី **អ៊ុក** **ហាន** អត្តលេខ ០០២៤៧៨ ជា នាយសេនាធិការរង
បញ្ជាការដ្ឋានកងទ័ពជើងអាកាស

១១-ឧត្តមសេនីយ៍ត្រី **អ៊ឹម** **សុជាតិ** អត្តលេខ ០០៣៨៤៧ ជា សាកលវិទ្យាធិការរង
សាកលវិទ្យាល័យការពារជាតិ

១២-ឧត្តមសេនីយ៍ត្រី **អ៊ុខ** **សួខ** អត្តលេខ ០០៤២៥១ ជា សាកលវិទ្យាធិការរង
សាកលវិទ្យាល័យការពារជាតិ

១៣-ឧត្តមសេនីយ៍ត្រី **ភូង** **វណ្ណារ៉ា** អត្តលេខ ០០៣២៣៦ ជា សាកលវិទ្យាធិការរង
សាកលវិទ្យាល័យការពារជាតិ

**មាត្រា២ ៈ** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធនិងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៥៥ អនក្រ.បក

## អនុក្រឹត្យ
## ស្តីពី
## ការតម្លើងឋានន្តរស័ក្តិមន្ត្រីនគរបាលជាតិកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ.បក ចុះថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា ១:** តម្លើងឋានន្តរស័ក្តិថ្នាក់ **វរសេនីយ៍ឯក** ជូននាយនគរបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា នៃក្រសួងមហាផ្ទៃ ៖

| | | | | |
|---|---|---|---|---|
| ១- | វរសេនីយ៍ទោ | **យិន** | **ធឿន** | អត្តលេខ ០២៨៥៨ |
| ២- | វរសេនីយ៍ទោ | **គង់** | **សុខុម** | អត្តលេខ ០២៨៦១ |
| ៣- | វរសេនីយ៍ទោ | **កែវ** | **ចន្ធី** | អត្តលេខ ០៣១៧៣ |
| ៤- | វរសេនីយ៍ទោ | **ពេជ្រ** | **វណ្ណៈ** | អត្តលេខ ០៤៣០៣ |
| ៥- | វរសេនីយ៍ទោ | **រឿម** | **ធុច** | អត្តលេខ ០៧៧៥៨ |
| ៦- | វរសេនីយ៍ទោ | **កើស** | **ចិន្តា** | អត្តលេខ ០៧៨១៩ |
| ៧- | វរសេនីយ៍ទោ | **អេង** | **ប៊ុនធឿន** | អត្តលេខ ០៧៨៦២ |
| ៨- | វរសេនីយ៍ទោ | **ម៉ាត់** | **ធុច** | អត្តលេខ ០៧៩០០ |
| ៩- | វរសេនីយ៍ទោ | **លឹម** | **ឆាយ** | អត្តលេខ ០៨២៧២ |
| ១០- | វរសេនីយ៍ទោ | **ហ៊ុន** | **វណ្ណា** | អត្តលេខ ០៨៥៨៧ |
| ១១- | វរសេនីយ៍ទោ | **យ៉ន** | **ឌីន** | អត្តលេខ ០៨៨៥២ |

១២- វរសេនីយ៍ទោ **ឃឿន ម៉ុនថេង** អត្តលេខ ០៨៨៥៣
១៣- វរសេនីយ៍ទោ **ធាន ប៉េងស៊ីន** អត្តលេខ ០៩១៧៣
១៤- វរសេនីយ៍ទោ **ទេព ចន្ទ័តារា** អត្តលេខ ០៩២០៣
១៥- វរសេនីយ៍ទោ **អ៊ូ ម៉ុណ្ណារ៉េត** អត្តលេខ ០៩២២៩
១៦- វរសេនីយ៍ទោ **ស៊ាត ធី** អត្តលេខ ០៩២៣០
១៧- វរសេនីយ៍ទោ **តាន់ ខាំភឿ** អត្តលេខ ០៩៣២៣
១៨- វរសេនីយ៍ទោ **មឿង សារិទ្ធ** អត្តលេខ ០៩៥៤២
១៩- វរសេនីយ៍ទោ **ផន សុផៃ** អត្តលេខ ០៩៥៦៣
២០- វរសេនីយ៍ទោ **ជុំ ចណ្ណា** អត្តលេខ ១០០៧៦
២១- វរសេនីយ៍ទោ **វ៉ាត់ ចន្ថា** អត្តលេខ ១០២៥៥
២២- វរសេនីយ៍ទោ **វៀម រ៉ា** អត្តលេខ ១០៤០៨
២៣- វរសេនីយ៍ទោ **លីម ចណ្ណៈ** អត្តលេខ ១០៨៥៦
២៤- វរសេនីយ៍ទោ **ណា ចេ** អត្តលេខ ១១៤០៤
២៥- វរសេនីយ៍ទោ **ស្វាយ ស៊ីម៉ុណ្ណា** អត្តលេខ ១១៤៧៥
២៦- វរសេនីយ៍ទោ **កែវ ពិជ** អត្តលេខ ១១៤៨៦
២៧- វរសេនីយ៍ទោ **សារ៉ាត់ ចិន្តា** អត្តលេខ ១៥៨៤៤
២៨- វរសេនីយ៍ទោ **តា សំអាត** អត្តលេខ ១៦៦១៥
២៩- វរសេនីយ៍ទោ **ស៊ុំ សុខហេង** អត្តលេខ ៣៥៤៩០
៣០- វរសេនីយ៍ទោ **ជួប តារុណា** អត្តលេខ ៣៦២៥៦
៣១- វរសេនីយ៍ទោ **ស៊ីវ សុជាតិ** អត្តលេខ ៥៤៩៤២
៣២- វរសេនីយ៍ទោ **ឆេន សុចត្ថិ** អត្តលេខ ៥៦៥៩៧
៣៣- វរសេនីយ៍ទោ **មីន រស្មី** អត្តលេខ ៥៩៨៦៧
៣៤- វរសេនីយ៍ទោ **ម៉ៅ សុផល** អត្តលេខ ៦១៧៧៥
៣៥- វរសេនីយ៍ទោ **ហេង រតនៈ** អត្តលេខ ៦៥៥៦៨ ។

**មាត្រា ២ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដែលមានចែងក្នុងមាត្រា ១ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០១៧*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៥៦ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយសុវត្ថារា

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១**._បំពាក់ **មេដាយសុវត្ថារា** ថ្នាក់ **ធិបឌិន្ទ** ជូននាយទាហាន ចំនួន២រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

១-ឧត្តមសេនីយត្រី **កែម ថន** សេនាធិការរង កងពលតូចថ្មើរជើងលេខ៧០

២-ឧត្តមសេនីយត្រី **សេង សាន** សេនាធិការរង កងពលតូចថ្មើរជើងលេខ៧០

**មាត្រា២**._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៤៧ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

**សម្រេច**

**មាត្រា១.** បំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូននាយទាហាន នាយទាហានរង និងពលទាហាន ចំនួន៥៥រូប ដែលមានស្នាដៃល្អក្នុងការបំពេញភារកិច្ចបម្រើជាតិមាតុភូមិ កន្លងមក ដូចមានរាយនាមខាងក្រោម ៖

**ក-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ទោ | **គន់** | **តៃឡេង** | នាយករងមន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២ | អនុសេនីយ៍ឯក | **ទ្រី** | **ណាន់** | រដ្ឋបាល មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៣ | អនុសេនីយ៍ត្រី | **ស៊ីន** | **ថាម្មុទ្ធិ** | នាយករងមណ្ឌលសុខភាពក្រាំងអំពិល កងពលតូចថ្មើរជើងលេខ៧០ |
| ៤ | អនុសេនីយ៍ឯក | **ជា** | **ញឹម** | រដ្ឋបាល មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៥ | អនុសេនីយ៍ឯក | **អ៊ុំ** | **គុយហ៊ាង** | ជំនួយការកុំព្យូទ័រ វរសេនាតូចលេខ៥ កងពលតូចថ្មើរជើងលេខ៧០ |
| ៦ | អនុសេនីយ៍ទោ | **គច់** | **ឥមឡុច** | នាយទាហាន កងពលតូចថ្មើរជើងលេខ៧០ |

**ខ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ទោ | **ប៊ុន** | **ខាន់អ៊ា** | នាយទាហាន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២ | វរសេនីយ៍ត្រី | **ប៊ូហ៊ាង** | **លីហេង** | នាយទាហាន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |

| | | | | |
|---|---|---|---|---|
| ៣ | វរសេនីយ៍ត្រី | អ៊ុច | សោភ័ណ | ពេទ្យមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៤ | វរសេនីយ៍ត្រី | យ៉ុន | យឹម | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៥ | អនុសេនីយ៍ឯក | ខាំ | ខ្មែរអន | នាយទាហាន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៦ | អនុសេនីយ៍ឯក | ចាន់ | ទេវ | ជំនួយការសុខាភិបាល មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៧ | អនុសេនីយ៍ឯក | សុទ្ធ | សុវណ្ណារ៉ា | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៨ | អនុសេនីយ៍ឯក | ម៉ិត | វាសនា | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ៩ | អនុសេនីយ៍ឯក | អឿ | យោន | ពេទ្យមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១០ | អនុសេនីយ៍ឯក | ស៊ុយ | ផល | នាយទាហាន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១១ | អនុសេនីយ៍ឯក | កុយ | រីណា | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ១២ | អនុសេនីយ៍ទោ | ទិត្យ | សុខន | ជំនួយការ ការិយាល័យទី១ កងពលតូចថ្មើរជើងលេខ៧០ |
| ១៣ | អនុសេនីយ៍ទោ | សេក | តារ៉ាត្ន | ជំនួយការ ការិយាល័យទី១ កងពលតូចថ្មើរជើងលេខ៧០ |
| ១៤ | អនុសេនីយ៍ទោ | ឈាន | ស៊ីណា | ជំនួយការ ការិយាល័យទី១ កងពលតូចថ្មើរជើងលេខ៧០ |
| ១៥ | អនុសេនីយ៍ទោ | ប្រាក់ | ឧត្តី | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៦ | អនុសេនីយ៍ទោ | ពៅ | សៅ | រដ្ឋបាល មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៧ | អនុសេនីយ៍ទោ | ខាន់ | សាខេម | នាយទាហាន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៨ | អនុសេនីយ៍ទោ | ម៉ាច | ដា | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៩ | អនុសេនីយ៍ទោ | អ៊ុច | ស្រីទូច | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២០ | អនុសេនីយ៍ទោ | លន់ | រចនៈ | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ២១ | អនុសេនីយ៍ត្រី | ស៊ុំ | មុនី | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២២ | អនុសេនីយ៍ត្រី | បូយ | ប៊ុនលាភ | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២៣ | អនុសេនីយ៍ត្រី | ហែម | មករា | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២៤ | អនុសេនីយ៍ត្រី | ប្រាក់ | សំបូរ | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២៥ | អនុសេនីយ៍ត្រី | ឈុន | សាវឿន | គិលានុប្បដ្ឋាកមធ្យម មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២៦ | អនុសេនីយ៍ត្រី | ម៉ែន | ធឿន | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ២៧ | ពលបាលត្រី | អៀម | ឌួងចាន់ | បម្រើការ មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |
| ២៨ | ពលបាលត្រី | យ៉ោក | សាវន | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ២៩ | ព្រិន្ទបាលទោ | សាំង | សារ៉ាយ | ជំនួយការផែន មន្ទីរពេទ្យ កងពលតូចថ្មើរជើងលេខ៧០ |

**គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ**

| | | | | |
|---|---|---|---|---|
| ១ | វរសេនីយ៍ទោ | យឹម | គឿន | មេបញ្ជាការកងតូច វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ២ | វរសេនីយ៍ទោ | ឃួន | វាសនា | នាយទាហាន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ៣ | វរសេនីយ៍ត្រី | លីម | សុខឃឿន | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ៤ | វរសេនីយ៍ត្រី | ភាំង | ស្រ៊ុន | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |

| | | | | |
|---|---|---|---|---|
| ៥ | អនុសេនីយ៍ឯក | **ផាន** | **សុផេណ្ណា** | ជំនួយការ ការិយាល័យហ្វឹកហ្វឺន កងពលតូចថ្មើរជើងលេខ៧០ |
| ៦ | អនុសេនីយ៍ឯក | **ផាត់** | **សុភា** | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ៧ | អនុសេនីយ៍ឯក | **ព្រាំ** | **ផល្លី** | ជ.ភស្តុភារ.បច្ចេកទេស វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ៨ | អនុសេនីយ៍ទោ | **ផូ** | **ពន្លឺ** | នាយទាហាន វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ៩ | អនុសេនីយ៍ទោ | **អ៊ិច** | **មករា** | មេបញ្ជាការកងតូច កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១០ | អនុសេនីយ៍ទោ | **ឈាច** | **ទូរ៉ា** | ជ.យន្តយុទ្ធ វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ១១ | អនុសេនីយ៍ត្រី | **យ៉ុម** | **ស្រីម៉ៃ** | បុគ្គលិក បម្រើការ ការិយាល័យទី៥ កងពលតូចថ្មើរជើងលេខ៧០ |
| ១២ | អនុសេនីយ៍ត្រី | **យូ** | **សុខហេង** | បុ.រដ្ឋបាល វរសេនាតូចលេខ១ កងពលតូចថ្មើរជើងលេខ៧០ |
| ១៣ | នាយចំណង់ | **ហ៊ីរ** | **សុភឥន** | បុគ្គលិក បម្រើការ ការិយាល័យទី៥ កងពលតូចថ្មើរជើងលេខ៧០ |
| ១៤ | ព្រិន្ទបាលទោ | **យឹង** | **ភារិន** | បុ.បើកបរ កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៥ | ព្រិន្ទបាលទោ | **កែន** | **សេរី** | យុទ្ធជន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៦ | ព្រិន្ទបាលទោ | **ហ៊ីន** | **សារឿន** | យុទ្ធជន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៧ | ព្រិន្ទបាលទោ | **មួង** | **រដ្ឋា** | យុទ្ធជន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៨ | ព្រិន្ទបាលទោ | **ធិន** | **សុខា** | យុទ្ធជន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |
| ១៩ | ព្រិន្ទបាលទោ | **នៅ** | **ដានី** | បុគ្គលិក បម្រើការ ការិយាល័យទី៥ កងពលតូចថ្មើរជើងលេខ៧០ |
| ២០ | ពលបាលត្រី | **ផា** | **ឥមពេជ្រ** | យុទ្ធជន កងអនុសេនាធំសង្គ្រោះអគ្គីភ័យ កងពលតូចថ្មើរជើងលេខ៧០ |

**មាត្រា២**.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការពារជាតិ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ : ១៤៤ ឧស.ក.ស.ប.ក.០៥

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៧

# ប្រកាសបង្កើតរោងចក្រ

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៨ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០១៤/០២៥ ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០១៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញសំណើសុំប្តូរប្រកាសបង្កើតរោងចក្រ ផលិតស្បែកជើង ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៧ របស់ក្រុមហ៊ុន ស៊ូព្រីមៀរ ធូ (ខេមបូឌា)

## សម្រេច

**ប្រការ១៖** អនុញ្ញាតឱ្យក្រុមហ៊ុន ស៊ូព្រីមៀរ ធូ (ខេមបូឌា) (SHOE PREMIER II (CAMBODIA) CO., LTD.) តំណាងដោយ លោក តាំង គួងហាវ បង្កើតរោងចក្រ ផលិតស្បែកជើង ដែលមានទីតាំងស្ថិតនៅភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

| ឈ្មោះផលិតផល | លេខកូដចំណាត់ថ្នាក់ឧស្សាហកម្ម ISIC Rev.4 Code |
|---|---|
| ស្បែកជើង | ១៥២០ |

៤៥ មហាវិថីព្រះនរោត្តម ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ : (៨៥៥)-២៣-២១១១៤១ , ទូរសារ : (៨៥៥)-២៣-៤២៨២៦៣
45 Preah Norodom Boulevard, Khan Daun Penh, Phnom Penh, Phone : 855-23-211141 , Fax: 855-23-428263

**ប្រការ២៖** ម្ចាស់រោងចក្រ ត្រូវលើកផ្លាកឈ្មោះរោងចក្រដូចមានចែងក្នុងមាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងដូចបានកំណត់ដោយឡែកនៅក្នុងសេចក្តីណែនាំស្តីពីការដាក់ឈ្មោះរោងចក្រ និងសិប្បកម្ម។

**ផ្លាកឈ្មោះរោងចក្រ៖** " រោងចក្រផលិតស្បែកជើង ស៊ូព្រីមៀរ ធូ (ខេមបូឌា) "

**ប្រការ៣៖** ការរៀបចំគ្រប់ផ្នែកក្នុងរោងចក្រ ត្រូវអនុលោមតាមមាត្រា៤នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ស្របទៅតាមប្លង់គ្រឿងចក្រ-គ្រឿងម៉ាស៊ីន ដែលបានតម្កល់នៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងបទបញ្ញត្តិបច្ចេកទេសដោយឡែករបស់ក្រសួង។

**ប្រការ៤៖** មុនចាប់ផ្តើមដំណើរការរោងចក្រ ម្ចាស់រោងចក្រត្រូវជូនដំណឹងឱ្យបានមុនរយៈពេល១៥ថ្ងៃ យ៉ាងតិច និងធ្វើការស្នើសុំវិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ ដែលមានសុពលភាព ០៣ឆ្នាំ ពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

**ប្រការ៥៖** ម្ចាស់រោងចក្រ ត្រូវតាំងបង្ហាញប្រកាសបង្កើតរោងចក្រ វិញ្ញាបនបត្រអនុញ្ញាតដំណើរការរោងចក្រ និងលិខិតអនុញ្ញាតទាំងឡាយ ជាចំហ នៅកន្លែងសមស្របណាមួយ ដែលងាយមើលឃើញក្នុងរោងចក្ររបស់ខ្លួន ស្របតាមមាត្រា១៦ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៦៖** ម្ចាស់រោងចក្រ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម លើការផ្លាស់ប្តូរទីតាំង ការពង្រីកផលិតកម្ម ការបង្កើតសាខារោងចក្រ ការប្តូរឈ្មោះរោងចក្រ ការបន្ថែមផលិតផលថ្មី និងការប្តូរម្ចាស់រោងចក្រ ស្របតាមមាត្រា១២ នៃច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងមាត្រា១៣ មាត្រា១៨ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៧៖** ម្ចាស់រោងចក្រ ត្រូវគ្រប់គ្រងរោងចក្រដោយខ្លួនឯង។ ក្នុងករណី ប្រគល់សិទ្ធិឱ្យអ្នកដទៃគ្រប់គ្រងរោងចក្រជំនួសខ្លួន ម្ចាស់រោងចក្រត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមកក្រសួងឧស្សាហកម្ម និងសិប្បកម្ម។ ក្នុងករណីនេះ ម្ចាស់រោងចក្រត្រូវតែទទួលខុសត្រូវលើគ្រប់សកម្មភាពនៃរោងចក្រ និងគុណភាពផលិតផលរបស់ខ្លួនចំពោះមុខច្បាប់ និងអ្នកប្រើប្រាស់ស្របតាមមាត្រា៥ នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៨៖** ម្ចាស់រោងចក្រ ត្រូវផ្តល់ឱ្យបានត្រឹមត្រូវ និងទៀងទាត់នូវទិន្នន័យ និងរបាយការណ៍ប្រចាំខែ មកអគ្គនាយកដ្ឋានឧស្សាហកម្ម នៅសប្តាហ៍ទីមួយនៃខែបន្ទាប់ ទៅតាមទម្រង់កំណត់របស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ស្របតាមមាត្រា១៩ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ៩៖** ម្ចាស់រោងចក្រ ត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសំណល់ឧស្សាហកម្មគ្រប់ប្រភេទ និងសុវត្ថិភាពឧស្សាហកម្ម តាមជំពូកទី៣នៃច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និងច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

**ប្រការ១០៖** ម្ចាស់រោងចក្រ ត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ច ស្របតាមមាត្រា៣៧ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម ឱ្យមានប្រសិទ្ធភាពខ្ពស់។

ម្ចាស់រោងចក្រ ត្រូវរាយការណ៍មកក្រសួងឧស្សាហកម្ម និងសិប្បកម្ម ឱ្យបានឆាប់រហ័សអំពីករណីប្រែប្រួលហានិភ័យ ឬករណីប្រធានសក្តិផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរបស់រោងចក្រ ស្របតាមមាត្រា៤១ នៃច្បាប់ ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម។

